# ភ្នំពេញ - ម៉ាឡេស៊ី (៤ថ្ងៃ៣យប់)

## ថ្ងៃទី១ : ភ្នំពេញ ~ គូឡាឡាំពួរ ~ ហ្គេនធីង



ជួបជុំគ្នានៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីបន្តដំណើរឆ្ពោះទៅកាន់ទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី។ ទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីសំណាក់មគ្គុទេសក៍ទេសចរដ៏ស្ទាត់ជំនាញ រួចបន្តទៅទស្សនាទៅកាន់ទីក្រុងរដ្ឋបាលថ្មីរបស់ប្រទេសម៉ាឡេស៊ី ពូត្រាចាយ៉ា រួចបន្តដំណើរទៅកាន់កំពូលភ្នំហ្គេនធីងជាតំបន់ទេសចរណ៍ដែលមានប្រជាប្រិយ៍ភាពបំផុតលំដាប់អន្តរជាតិដែលមានកំពស់២០០០ម៉ែត្រពីលើរយ:កំពស់នៃទឹកសមុទ្រ។ រីករាយនិងសាកល្បងសំណាងរបស់អ្នកនៅកាស៊ីណូដែលមានតែមួយ នៅម៉ាឡេស៊ី រីករាយជាមួយការជិះកន្រ្តក់វិលដែលមានល្បឿនលឿននិងចំងាយឆ្ងាយជាងគេនៅទ្វីបអាស៊ីហើយគយគន់ទេសភាពដ៏ស្រស់ត្រកាល និងកំសាន្តជាមួយល្បែងកំសាន្តសំរាប់មនុស្សគ្រប់វ័(ចំណាយប្រាក់ផ្ទាល់ខ្លួន)។

## ថ្ងៃទី២ : ហ្គេនធីង ~ គូឡាឡាំពួរ ~ ម៉ាឡាកា (អាហារ ៣ពេល)



អាហារពេលព្រឹករួចជូនទៅទស្សនាកំសាន្ត និងថតរូបភាពនៅសួនច្បារដ៏ស្រស់ត្រកាលនៃ **Theme Park** រួចបន្តទៅទីក្រុងគូឡាឡាំពួរនិងទស្សនារូងភ្នំខ្យល់ខ្មៅឬបាធូរោងចក្រសំណរប៉ាហាំងនិងហាងលក់គ្រឿងអលង្ការ...។ បន្តដំនើរទៅទីក្រុងចំណាស់ម៉ាឡាកា យើងទៅទស្សនាវិថីចុងគីរមណីយដ្ឋានអេហ្វាម៉ូសាវ៉ដែលលាតសន្ធឹងលើ ផ្ទៃដី ៥២០ហិចតា ហើយ នៅក្នុងនោះយើងអាចកំសាន្តជាមួយពិភពសត្វព្រៃទីក្រុងខោប៊យពិភពសួនទឹកនិងទស្សនាការសំដែងរបស់តួខោប៊យការសំដែងរបស់សត្វដ៏ឆ្លាតការសំដែងរបស់សត្វដំរីការសំដែងរបស់ក្រុង **Wild-Wild West** និងការជិះដែងដ៏អស្ចារ្យជាច្រើនទៀត។ ជាពិសេសជាងនេះទៅទៀតយើងអាចទស្សនាខ្សែភាពយន្ត៤ឌនៅទីនោះផងដែរ។ បន្តទស្សនាព្រះវិហារចេងហួនតេង ឆាយណាថោននិងហាងលក់ផលិតផលក្នុងស្រុក។

## ថ្ងៃទី៣ : ម៉ាឡាកា ~ គូឡាឡាំពួរ (អាហារ ៣ពេល)



ស្រស់ស្រូបអាហារពេលព្រឹក រួចបន្តដំនើរត្រលប់មកកាន់ទីក្រុងគូឡាឡាំពួរ ។ រួចបន្តទស្សនាទីក្រុងកូឡាឡាំពួរ វិមានផានហ័រ វិមានរដ្ឋសភាទីលានឯករាជ្យ ព្រះរាជវាំង វិមានឯករាជ្យ ផ្ទះសូកូឡា និង ទៅថ្តិតយករូបភាពដ៏ស្រស់ត្រកាលនៃ អាគារភ្លោះ ដែលមានកំពស់ខ្ពស់ជាងគេរហូតដល់៨៨ជាន់ ហើយជូនទៅកំសាន្តនៅ ផ្សារទំនើប **Suria KLCC**។ អាហារល្ងាច រួចជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៤ : គូឡាឡាំពួរ ~ ភ្នំពេញ (អាហារ ១ពេល)



ស្រស់ស្រូបអាហារពេលព្រឹក រួចបន្តដំនើរត្រលប់មកព្រលានយន្តហោះ ដើម្បីបន្តដំនើរត្រលប់មកកាន់រាជធានីភ្នំពេញប្រកបដោយសុវត្ថិភាព និងស្នាមញញឹម ។

ដំណើរកំសាន្តរួមមាន :

- ☞ សំបុត្រយន្តហោះទៅមក
- ☞ សណ្ឋាគារផ្កាយ៣ បន្ទប់១ គេង២នាក់
- ☞ អាហារ៣ពេល និងសំបុត្រចូលទស្សនា
- ☞ មធ្យោយធ្វើដំណើរ និងមគ្គុទេសក៏ទេសចរណ៍

ដំណើរកំសាន្តមិនរាប់បញ្ចូលមាន :

- ☞ទិដ្ឋាការ និងពន្ធព្រលានយន្តហោះ $18
- ☞ប្រាក់ទឹកតែសំរាប់ មគ្គុទេសក៏ $10
- ☞ថ្លៃធានារ៉ាប់រងលើសំបុត្រយន្តហោះ $22
- ☞សេវាកម្មផ្សេងៗ $7
- ☞ភេសជ្ជ: និងរាល់ការចំណាយផ្ទាល់ខ្លួន

បញ្ជាក់:

☞ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។

☞សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់

**ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង**

ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩

អ៊ីមែល: book@asiaexplorertravel.com